# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៩.០១៩/០៧ គជប.អគ្គ.ពស** ភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៧

## គ.ជ.ប ផ្សព្វផ្សាយពីការដាក់ភ្នាក់ងារសង្កេតការណ៍

នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៧ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ( គ.ជ.ប ) បានរៀបចំកិច្ចប្រជុំមួយជាមួយតំណាងគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្សព្វផ្សាយអំពីការដាក់ភ្នាក់ងារសង្កេតការណ៍ សម្រាប់ពិនិត្យមើលដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ២០០៧ និងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ ឆ្នាំ ២០០៨ ។

លោកជំទាវ ស៊ីន ជុំបូ អនុប្រធាន គ.ជ.ប បានមានប្រសាសន៍ក្នុងកិច្ចប្រជុំនោះថា ការដាក់ពាក្យសុំចុះឈ្មោះតំណាងគណបក្សនយោបាយ ដើម្បីពិនិត្យមើលដំណើរការបោះឆ្នោតមានពីរដំណាក់កាល ។ ដំណាក់កាលទី១ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត គណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ស្តីពីគណបក្សនយោបាយ មានសិទ្ធិចាត់តាំងតំណាងពេញសិទ្ធិរបស់ខ្លួនមួយរូប និងបំរុងមួយរូប ដើម្បីសង្កេតការណ៍នៅក្នុងដំណាក់កាលនេះ ។ ពាក្យសុំចុះឈ្មោះនេះត្រូវដាក់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ តាមទម្រង់បែបបទ លេខ ១០០៧ ចាប់ពីថ្ងៃទី ៧ ខែ កញ្ញា ដល់ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៧ ហើយពាក្យសុំនេះ ត្រូវចុះហត្ថលេខាដោយប្រធាន ឬតំណាងគណបក្សនយោបាយ ដែលត្រូវបានទទួលការផ្ទេរសិទ្ធិជាលាយល័ក្ខណ៍អក្សរពី ប្រធានគណបក្ស ។ ដំណាក់កាលទី២ គឺការបោះឆ្នោត និងរាប់សន្លឹកឆ្នោត គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០០៨ មានសិទ្ធិបញ្ជូនតំណាងពេញសិទ្ធិមួយរូប និងបំរុងមួយរូប ក្នុងចំណោមអ្នកមានសិទ្ធិបោះឆ្នោត ដើម្បីចូលរួមសង្កេតមើលការបោះឆ្នោត តាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ក្នុងមណ្ឌលខេត្ត ក្រុងដែលបេក្ខជនរបស់គណបក្សនោះបានឈរឈ្មោះបោះឆ្នោត ។ ពាក្យសុំចុះឈ្មោះជាតំណាងត្រូវដាក់ទៅគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ចាប់ពីថ្ងៃទី ២៧ ខែ មិថុនា រហូតដល់ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៨ ហើយពាក្យសុំនេះ ត្រូវចុះហត្ថលេខាដោយប្រធាន ឬតំណាងគណបក្សនយោបាយ ដែលត្រូវបានទទួលការផ្ទេរសិទ្ធិជាលាយល័ក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយ ។

លោកជំទាវបានបញ្ជាក់ទៀតថា ចំពោះសមាគមន៍ ឬអង្គការមិនមែនរដ្ឋាភិបាលជាតិ ដែលមានបំណងបញ្ជូនតំណាងឱ្យចូលរួមសង្កេតការណ៍បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវដាក់ពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍មក គ.ជ.ប ចាប់ពីថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៧ រហូតដល់ថ្ងៃ ទី ២០ ខែ កក្កដា ឆ្នាំ ២០០៨ ។ ដោយឡែកចំពោះអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងប្រទេសនានា ដែលមានបំណងសង្កេតការណ៍បោះឆ្នោត ត្រូវដាក់ពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍មក គ.ជ.ប ចាប់ពីថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០០៧ រហូតដល់ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៨ ។

ក្នុងកិច្ចប្រជុំនោះតំណាងគណបក្សនយោបាយបានស្នើសុំឱ្យ គ.ជ.ប ណែនាំដល់ស្មៀន និងក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យគោរពពេលវេលារបស់ខ្លួនក្នុងការអនុវត្តការងារចុះឈ្មោះបោះឆ្នោត ។

ទាក់ទងនឹងការលើកឡើងរបស់គបក្សនយោបាយនេះ ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៍ថា គ.ជ.ប បានចេញសេចក្តីណែនាំមួយចំនួនទាក់ទងនឹងភារកិច្ចរបស់ស្មៀនឃុំ សង្កាត់ និងក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងពេលអនុវត្តការងារចុះឈ្មោះបោះឆ្នោតនេះ ។ ឯកឧត្តមបានបន្តថា គ.ជ.ប នឹងធ្វើការសហការជាមួយក្រសួងមហាផ្ទៃ ចេញសេចក្តីណែនាំបន្ថែមទៀតទាក់ទងទៅនឹងភារកិច្ចរបស់ស្មៀន និងក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឱ្យដំណើរការចុះឈ្មោះបោះឆ្នោតនេះប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធិភាព ។